## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ
លេខ : 688
ចុះថ្ងៃទី 22-03-2009
ជំរះលេខ 873
ចុះថ្ងៃទី 12-06-2009
-សាលក្រមលេខ: ៨៣ "កប៥"
ចុះថ្ងៃទី ០៨-០៩-២០០៩

## **សាលក្រម ក្នុងនាមប្រជារាស្ត្រខ្មែរ**

## **សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៨-០៩-២០០៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក មានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជំរះ**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ (ជាប្រធាន)

-លោកស្រី [redacted] ក្រមសាលាដំបូងរាជធានីភ្នំពេញ (ជាសមាជិក)

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ (ជាសមាជិក)

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨៨ ចុះថ្ងៃទី ២២-០៣-២០០៩ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីនៅផ្ទះ កើតនៅភូមិរកាកោង ឃុំរកាកោង ស្រុកមុខកំពុល ខេត្តកណ្ដាល ទីលំនៅមុនពេលចាប់ខ្លួនផ្ទះជួល សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី ២០-០៣-២០០៩

ដីកាបង្គាប់ឱ្យឃុំលេខ ៧៤៩ ត.ព្រ ចុះថ្ងៃទី ២៣-០៣-២០០៩ ។

មេធាវីការពារជនជាប់ចោទ: លោក **អ៊ូ សោភ័ណ្ឌ៉ា** ។

២-ឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីមិនពិតប្រាកដ កើតនៅភូមិកណ្ដាល ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តកណ្ដាល ទីលំនៅមុនពេលចាប់ខ្លួនផ្ទះជួល សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី ២០-០៣-២០០៩

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៥១ ត.ព្រ ចុះថ្ងៃទី ២៣-០៣-២០០៩ ។

មេធាវីការពារជនជាប់ចោទ: លោក [redacted] ។



Scanned by CamScanner

៣-ឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីជាងកាត់សក់ កើតនៅភូមិកណ្ដាល ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តកណ្ដាល ទីលំនៅមុនពេលចាប់ខ្លួនផ្ទះជួល សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី ២០-០៣-២០០៩

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៥០ ត.ព្រ ចុះថ្ងៃទី ២៣-០៣-២០០៩ ។

មេធាវីការពារជនជាប់ចោទៈ លោក [redacted] ។

ជាប់ចោទពីបទ **ប្លន់(ឆក់ខ្សែក)** ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០-០៣-២០០៩ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិនៃមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៤៥ឆ្នាំ មានទីលំនៅផ្ទះលេខ៣E, ផ្លូវ៣១៦ ក្រុមទី៣៦ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញដីកាអមលេខ ០២៣ ជអ ចុះថ្ងៃទី ២២-០៣-១០០៩ របស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ រាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៣៩ អ.យ.ឆ ចុះថ្ងៃទី ២៣-០៣-២០០៩ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៩៨១ អ.យ.ឆ ចុះថ្ងៃទី ០៥-០៦-២០០៩ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៨៧០០ ត.ព្រ ចុះថ្ងៃទី ១១-០៦-២០០៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី ២០-០៣-២០០៩ វេលាម៉ោង ២០:០០ នាទី កំលាំងល្បាតរបស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាលបានធ្វើការចាប់ខ្លួនជនល្មើសចំនួន០៣គឺឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ដែលបានធ្វើសកម្មភាព ឆក់ខ្សែករបស់ជនរងគ្រោះឈ្មោះ [redacted] ស្រី អាយុ៤៥ឆ្នាំ នៅចំនុច បេនឡានអូឡាំពិក។

**នាពេលសួរចម្លើយ**

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយ នៅថ្ងៃកើតហេតុឈ្មោះ [redacted] និងឈ្មោះ [redacted] បានជិះម៉ូតូទៅបបួលខ្លួននៅផ្ទះទៅផឹកនៅពោធិ៍ចិនតុង ។ ពេលចាប់ខ្លួនខ្សែកនៅក្នុងហោប៉ៅរបស់ឈ្មោះ [redacted] ដោយខ្លួនជាអ្នកឌុបឈ្មោះ [redacted] ។ ខ្លួនបានឃើញសមត្ថកិច្ចប្រគល់ខ្សែកអោយទៅជនរងគ្រោះ ហើយខ្លួនពុំដឹងថា ឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើសកម្មភាពឆក់តាំងពីពេលណាទេ ។ ខ្លួនសុំបញ្ជាក់ថា ខ្លួនពុំបានចូលរួមធ្វើសកម្មភាពឆក់គេ ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនពុំបានដឹងពីសកម្មភាពឆក់ខ្សែកទេ ព្រោះខ្លួនជិះម៉ូតូដាច់ពីឈ្មោះ [redacted] ឆ្ងាយមើលពុំឃើញទេ។ ខ្លួនសុំបដិសេធការឆក់ខ្សែកនេះព្រោះខ្លួនពុំបានដឹងទេ ។



Scanned by CamScanner

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនបានធ្វើសកម្មភាពឆក់នៅថ្ងៃទី ២០-០៣-២០០៩ នៅបេនឡានអូឡាំពិក ខ្លួនបានទូរស័ព្ទប្រាប់ឈ្មោះ [redacted] អោយមកជិក ។ ខ្លួនបានធ្វើសកម្មភាពឆក់តែម្តងទេ ពេលធ្វើសកម្មភាពឈ្មោះ [redacted] ជាអ្នកឌុបខ្លួនហើយម៉ូតូជារបស់ឈ្មោះ [redacted] ដោយស្រុះស្រួលគ្នាទាំងអស់។ ពេលឆក់បានហើយម៉ូតូទាំងពីរគ្រឿងដែលមានឈ្មោះ [redacted] ជិះទៅស្របគ្នាតែម្តង ឈ្មោះ [redacted] បានដឹងហើយដែលមុនពេលធ្វើសកម្មភាពឆក់ព្រោះខ្លួនបាននិយាយស្រុះស្រួលគ្នាទាំងបីនាក់រួចហើយ ។ ពេលធ្វើសកម្មភាពឆក់ជនរងគ្រោះពុំបានដួលទេ ។ ខ្លួនបានណាត់គ្នាដោយអោយឈ្មោះ [redacted] ជិះបិតគូទពីក្រោយ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សមត្ថកិច្ចនគរបាល និងចៅក្រមស៊ើបសួរបានឆ្លើយថា នៅថ្ងៃទី២១-០៣-២០០៩ ខ្លួនបានជិះម៉ូតូចេញពីផ្ទះទៅជិកកូនចេញពីរៀននៅសាលាទួនហ្វា លុះធ្វើដំណើរដល់ចំនុចបេនឡានអូឡាំពិកកំត្រូវជនល្មើសចំនួនពីរនាក់ជិះម៉ូតូពីរគ្រឿងធ្វើសកម្មភាពឆក់ខ្សែកខ្លួនរួចជិះគេចខ្លួនបាត់។ ជនល្មើសដែលបានឆក់ខ្សែកខ្លួននោះគឺជិះម៉ូតូមានគ្នា០២នាក់។ ពេលដែលក្រុមជនល្មើសឆក់ខ្សែកខ្លួននោះខ្លួនពុំបានដឹងថាមានគ្នាវាជិះពីក្រោយខ្លួនទេ ចំណែកខ្សែកដែលឆក់បានគឺកាន់នៅហ្នឹងដៃដោយពុំបានជ្រុះទៅណាទេ ។នៅពេលពេលប៉ូលីសហៅខ្លួនទៅយកខ្សែកទើបខ្លួនដឹងថា ក្រុមជនល្មើសមានគ្នា៣នាក់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា យោងតាមដីកាសន្និដ្ឋានស្ថាពរលេខ ៩៨១ អ.យ.ឆ ចុះថ្ងៃទី ០៥-០៦-២០០៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៨៧០០ ត.ព្រ ចុះថ្ងៃទី ១១-០៦-២០០៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់ទៅលើជនជាប់ចោទ៣រូបគឺ ១-ឈ្មោះ [redacted] ២-ឈ្មោះ [redacted] និង [redacted] ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ការ អានកំណត់ហេតុរបស់ក្រឡាបញ្ជីតំណាងអយ្យការយល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទទាំងបីរូប ដែលបានឆ្លើយរួចហើយនៅចៅក្រមស៊ើបសួរ តែនាពេលសវនាការបានឆ្លើយបដិសេធ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] បានទទួលស្គាល់ថាខ្លួននិងឈ្មោះ [redacted] បានធ្វើសកម្មភាពឆក់មែន និងឆ្លើយសារភាពដូច្នេះ ។ ចំលើយដែលជនជាប់ចោទទាំងបីនាក់ឆ្លើយសារភាពនៅ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅតែមានសុពលភាពដដែល ដោយពុំមានភស្តុតាងផ្ទុយណាមួយសំរាប់បញ្ជាក់ទេ ហេតុដូច្នេះតំណាងអយ្យការសុំតំកល់ការចោទប្រកាន់នៅដដែល និងសុំឱ្យក្រុមប្រឹក្សាជំនុំជំរះសំរេចផ្តន្ទាទោសទៅតាមច្បាប់ ។

-មេធាវីការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយនាពេលសវនាការថ្ងៃនេះឃើញថាឈ្មោះ [redacted] បានជិះម៉ូតូជាមួយឈ្មោះ [redacted] ហើយឈ្មោះ [redacted] បានជិះម៉ូតូដាច់ពីគ្នាជាម៉ូតូរបស់ឈ្មោះ [redacted] យសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] និង [redacted] ហើយខ្លួនសុំបញ្ជាក់ថា [redacted] កើតនៅឆ្នាំ១៩៩២ ដូច្នេះឈ្មោះ [redacted] ស្ថិតនៅក្នុងសិទ្ធិកុមារដោយភ្ជាប់មកជាមួយនូវសំបុត្រកំណើត កាតសិស្ស និងសៀវភៅគ្រួសារ ស្នើសុំឱ្យតុលាការលើកលែងចោទដល់ឈ្មោះ [redacted] និងបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនទាំងពីរនាក់ដែលបានឆ្លើយសារភាព ។



Scanned by CamScanner

-ជនជាប់ចោទឈ្មោះ [redacted]ននិយាយសំដីចុងក្រោយរបស់ខ្លួនថា សុំឱ្យតុលាការលើកលែងទោសដល់ខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-ជនជាប់ចោទឈ្មោះ[redacted]ាននិយាយសំដីចុងក្រោយរបស់ខ្លួនថា សុំឱ្យតុលាការលើកលែងទោសដល់ខ្លួនផងព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-ជនជាប់ចោទឈ្មោះ[redacted]បាននិយាយសំដីចុងក្រោយរបស់ខ្លួនថា សុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ព្រោះខ្លួនទើបតែប្រព្រឹត្តលើកទីមួយតែប៉ុណ្ណោះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯសារភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**

-តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ អំពើប្លន់ ជាការបន្លំ និងជាជីវិតយកទ្រព្យសម្បត្តិអ្នកដទៃតាមគ្រប់រូបភាពដោយផ្ទាល់ក្តី ដោយប្រយោលក្តីក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ។

-តាមចម្លើយរបស់ឈ្មោ[redacted]បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថា ខ្លួន និងឈ្មោះ [redacted]ានស្រុះស្រួលគ្នាជាមុនដើម្បីធ្វើសកម្មភាពប្លន់ខ្សែករបស់ជនរងគ្រោះនៅពេលខ្លួនឃើញជនរងគ្រោះពាក់ខ្សែរកជិះម៉ូតូតែម្នាក់ឯងខ្លួនបានអោយឈ្មោះ[redacted]បម៉ូតូក្បែរជនរងគ្រោះដើម្បីឆក់ខ្សែករពិតប្រាកដមែន ហើយឈ្មោ[redacted]អ្នកជិះម៉ូតូបិទគូទពីក្រោយ ។

-តាមចម្លើយរបស់ឈ្មោះ[redacted]នាពេលសវនាការថា ខ្លួនពុំបានចូលរួមធ្វើសកម្មភាពជាមួយឈ្មោះ [redacted]។ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទនៅសមត្ថកិច្ចនគរបាលបានបញ្ជាក់ថាជនជាប់ចោទរូបនេះបានចូលរួមធ្វើកម្មភាពជាមួយឈ្មោះ [redacted]ប្លន់ខ្សែកពីជនរងគ្រោះ។ តាមមាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ជនជាប់ចោទនិងមេធាវីការពារជនជាប់ចោទពុំមានភស្តុតាងផ្ទុយណាមកបញ្ជាក់ក្រៅពីតែចម្លើយរបស់ជនជាប់ចោទដែលពុំអាចឱ្យតុលាការជឿបានទេ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]នាពេលសវនាការក៏បានបដិសេធពីការចូលរួមរបស់ខ្លួននៅក្នុងសកម្មភាពប្លន់ខ្សែកពីជនរងគ្រោះដែរតែចម្លើយរបស់ជនជាប់ចោទទាំងបីនាក់នៅសមត្ថកិច្ចមានលក្ខណៈស៊ីសង្វាក់ដែលបង្ហាញឱ្យឃើញពីតួនាទីការណ៍ ក្នុងការធ្វើសកម្មភាពប្លន់ខ្សែកពីជនរងគ្រោះ។



Scanned by CamScanner

-តាមចម្លើយរបស់ជនជាប់ចោទនៅសមត្ថកិច្ចនគរបាលមានលក្ខណៈស៊ីសង្វាក់គ្នាទៅ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី អាចឱ្យតុលាការកំណត់បានថា ជនជាប់ចោទទាំងបីនាក់ពិតជាបានរួមគំនិតគ្នាដើម្បីឆក់ខ្សែកពីជនរងគ្រោះ ។

-ជនជាប់ចោទទាំង០៣នាក់ត្រូវសមត្ថកិច្ចចាប់ខ្លួនបានជាក់ស្តែង និងដកហូតបានវត្ថុតាងមួយចំនួន ។

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ,ឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជានីតិជនអាចទទួលខុសត្រូវលើព្រហ្មទណ្ឌបាន ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពេលខ្លួនធ្វើដំណើរដល់ចំនុចបេនឡានអូឡាំពិកក៏ត្រូវជនល្មើសចំនួនពីរនាក់ជិះម៉ូតូពីរគ្រឿងធ្វើសកម្មភាព ឆក់ខ្សែកខ្លួនរួចជិះគេចខ្លួនបាត់ ។

-មានពិរុទ្ធភាព និងភស្តុតាងជាក់ប្រាកដគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ,ឈ្មោះ [redacted] អាយុ២៣ឆ្នាំ និងឈ្មោះ [redacted] ប្រុស អាយុ២៣ឆ្នាំ ពីបទ **ប្លន់ (ឆក់ខ្សែក)** រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០-០៣-២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីការបន្ធូរទំងន់ទោសនៃបទឧក្រិដ្ឋ ។

-អំពើរបស់ជនជាប់ចោទទាំងបីនាក់បានរំលោភទៅលើទ្រព្យសម្បត្តិស្របច្បាប់របស់បុគ្គល ប៉ះពាល់ដល់សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មិនបានចូលមកឆ្លើយក្នុងពេលសវនាការនិងមិនមានចម្លើយណាមួយដែលទាក់ទងនិងបញ្ហាសំណងទេ ហេតុដូច្នេះតុលាការមិនពិចារណាលើបញ្ហាសំណងទេ។

-វត្ថុតាងដែលសមត្ថកិច្ចដកហូតបានរួមមាន:

១-ម៉ូតូ០១គ្រឿងម៉ាក ... ពណ៌ខ្មៅ ស៊េរីឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 1O 6290 លេខតួ និងលេខម៉ាស៊ីន E450TH2..0793 ។

២-ម៉ូតូ០១គ្រឿងម៉ាក C1.. ពណ៌ខ្មៅ ស៊េរីឆ្នាំ១៩៩៩ ផលិតនៅប្រទេសចិន ពាក់ផ្លាកលេខ ណា 3462 ភព១ ដែលមានលេខតួ និងលេខម៉ាស៊ីន EPSOMG-3*10472044* ម៉ូតូទាំងពីរគ្រឿងនេះជនជាប់ចោទប្រើប្រាស់ជាមធ្យោបាយដើម្បីប្រព្រឹត្តបទល្មើស គប្បីរឹបអូសទុកជាសម្បត្តិរដ្ឋ ។

៣-ខ្សែកផ្លាក់ទីនចំនួន០១ខ្សែ ប្រវែង ២តឹកកន្លះ ជារបស់ជនរងគ្រោះ ត្រូវបាននគរបាលព្រហ្មទណ្ឌកិតស្រាលប្រគល់ឱ្យជនរងគ្រោះរួចរាល់តាមកំណត់ហេតុប្រគល់ចុះថ្ងៃទី ២១-០៣-២០០៩ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នៅសមត្ថកិច្ចនគរបាលបានឆ្លើយថា ខ្លួនធ្លាប់ប្រព្រឹត្តបទល្មើសចំនួន ៣លើកមកហើយ ចំណែកឯឈ្មោះ [redacted] ក៏ដូចជាឈ្មោះ [redacted] នាពេលសវនាការបានឆ្លើយបដិសេធចម្លើយដែលបង្កប់ [illegible] ដល់ការពិចារណា រីឯឈ្មោះ [redacted] បានឆ្លើយសារភាពចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ដូចនេះគប្បីតុលាការពិចារណាទៅតាមស្ថានភាពរបស់ជនជាប់ចោទនីមួយៗ ។

**សាលាដំបូងរាជធានីភ្នំពេញ**

**សម្រេចសេចក្តី**

១-ផ្តន្ទាទោសលើ:

ក-ឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៧ ឆ្នាំ (ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ..-០៣-២០០៩ ។



Scanned by [redacted]

ខ-ឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៦ ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២០-០៣-២០០៩ ។

គ-ឈ្មោះ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២០-០៣-២០០៩ ពីបទ **ប្លន់(ឆក់ខ្សែក)** ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០-០៣-២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-វត្ថុតាងរួមមាន:

-ម៉ូតូ០១គ្រឿងម៉ាក ស្មាសវ៉ែ ពណ៌ខ្មៅ សេរីឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 1O 6290 លេខតួ និងលេខម៉ាស៊ីន E450TH210793 ។

-ម៉ូតូ០១គ្រឿងម៉ាក C110 ពណ៌ខ្មៅ សេរីឆ្នាំ១៩៩៩ ផលិតនៅប្រទេសចិន ពាក់ផ្លាក់លេខ ណា 3462 ភព១ ដែលមានលេខតួ និងលេខម៉ាស៊ីន EPSOMG-3*10472044* ។

ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

-ខ្សែកផ្លាកទីនចំនួន០១ខ្សែ ប្រវែង ២តឹកកន្លះ ត្រូវប្រគល់ឱ្យឈ្មោះ [redacted] កំណត់ហេតុប្រគល់សម្ភារៈចុះថ្ងៃទី ២១-០៣-២០០៩ របស់ការិយាល័យព្រហ្មទណ្ឌកិរិតស្រាល រួចហើយ ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៨-០៩-២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ជាពិការពារ កំពុំងមុខ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ ថ្ងៃទី 15 ខែ ០៩ ឆ្នាំ២០០៩

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner